ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## កម្រងការឯកសារ និងទីកន្លែងស្នើសុំ "លិខិតអនុញ្ញាតចេញ-ចូល" រោងចក្រ សហគ្រាស និងសិប្បកម្ម ដែលត្រូវបានអនុញ្ញាតឱ្យដំណើរការក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ជាបណ្តោះអាសន្ននៅភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមជម្រាបជូនលោក លោកស្រី ជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្ម ដែលត្រូវបានអនុញ្ញាតឱ្យដំណើរការអាជីវកម្ម និងបុគ្គលិកចាំបាច់បំផុតនៃរោងចក្រ សហគ្រាស និងសិប្បកម្ម ដែលត្រូវបានឱ្យផ្អាកដំណើរការអាជីវកម្ម ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ជាបណ្តោះអាសន្ននៅភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៤២/២១ក.ប/ស.ស.រ.ខ.ល ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ ឱ្យបានជ្រាបថា ដើម្បីទទួលបាននូវ "លិខិតអនុញ្ញាតចេញ-ចូល" លោក លោកស្រី៖

១. ត្រូវយកឯកសារបើកសហគ្រាស និងបញ្ជីឈ្មោះកម្មករនិយោជិត និងបុគ្គលិក ដែលត្រូវធ្វើដំណើរមកបំពេញការងារក្នុងអំឡុងពេលបិទខ្ទប់។

២. ត្រូវចាត់តំណាង១រូប មកស្នើសុំនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់រោងចក្រ សហគ្រាស សិប្បកម្មនៅរាជធានីភ្នំពេញ និងមកស្នើសុំនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល សម្រាប់រោងចក្រ សហគ្រាស សិប្បកម្មនៅក្រុងតាខ្មៅ។

បន្ថែមលើ "លិខិតអនុញ្ញាតចេញ-ចូល" នេះ លោក លោកស្រី ព្រមទាំងកម្មករ និយោជិត និងបុគ្គលិក ត្រូវយកតាមខ្លួនផងដែរនូវបណ្ណការងារ ឬបណ្ណបុគ្គលិក និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដើម្បីបង្ហាញជូនសមត្ថកិច្ច។

ជនទាំងឡាយណាដែលក្លែង "លិខិតអនុញ្ញាតចេញ-ចូល" ឬប្រើលិខិតនេះ ខុសពីគោលបំណងដើមត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងលេខទូរស័ព្ទ៖

- **012 436 143/098 700 542** សម្រាប់រោងចក្រ សហគ្រាស និងសិប្បកម្ម នៅរាជធានីភ្នំពេញ
- **015 292 929 /012 687 853** សម្រាប់រោងចក្រ សហគ្រាស និងសិប្បកម្ម នៅក្រុងតាខ្មៅនៃខេត្តកណ្តាល

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្ម ជ្រាបជាព័ត៌មាន និងមកចុះឈ្មោះស្នើសុំលិខិតអនុញ្ញាតចេញ-ចូលនេះតាមទីតាំងដែលបានកំណត់ និងតាមការចាំបាច់។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥